# បច្ចេកទេសប្រមូលយកទឹកឃ្មុំព្រៃប្រកបដោយនិរន្តរភាព

## *Sustainable Wild Honey technical collection*

ធ្វើបទបង្ហាញដោយៈ លោកស្រី កាន់ សីមា



# មាតិកា

| | |
|---|---|
| ១.សេចក្តីផ្តើម | |
| ២.ភាពគំរាមគំហែង | ៦.បច្ចេកទេសការប្រមូលនិងការគ្រប់គ្រងទឹកឃ្មុំប្រកបដោយនិរន្តរភាព |
| ៣.លក្ខណៈជីវសាស្រ្តរបស់សត្វឃ្មុំព្រៃ | ក) លក្ខខណ្ឌឃ្មុំព្រៃ |
| ៤.ប្រភេទសត្វឃ្មុំនៅកម្ពុជា | ៦.១ ការកែច្នៃនិងការត្រួតពិនិត្យគុណភាពទឹកឃ្មុំ<br>៦.២ របៀបច្រោះទឹកឃ្មុំព្រៃ<br>៦.៣ ការចម្រោះទឹកឃ្មុំព្រៃលើកទី២ និងការត្រួតពិនិត្យទឹកឃ្មុំព្រៃ<br>៦.៤ ការវិចខ្ចប់ទឹកឃ្មុំព្រៃ |
| ៥. អត្ថប្រយោជន៍ឃ្មុំនិងទឹកឃ្មុំព្រៃ | ៧. របៀបធ្វើបង្កងឱ្យឃ្មុំធំនៅក្នុងព្រៃសហគមន៍ |
| | |

# ១.សេចក្តីផ្តើម



ការរប្រមូលទឹកឃ្មុំព្រៃគឺជាប្រពៃណីដ៏យូលង់ណាស់មកហើយ  សម្រាប់អ្នកប្រមូលឃ្មុំព្រៃ នៅក្នុងសហគមន៍ដែលពឹងអាស្រ័យលើព្រៃឈើនៅក្នុងប្រទេសកម្ពុជា ជាពិសេសជនជាតិដើមភាគតិច។ តាមទំនៀមទំលាប់ខ្មែរយើងតាំងពីបុរាណ ទឹកឃ្មុំដែលយកបានមកពីព្រៃត្រូវបានយកទៅប្រើប្រាស់ជាឱសថ ឬជាអាហារ ។ ការធ្វើអាជីវកម្មលើទឹកឃ្មុំព្រៃបានធ្វើឱ្យវិធីសាស្រ្តនៃការប្រមូលយកឃ្មុំព្រៃប្រកបដោយនិរន្តរភាពមានការប្រែប្រួល ហើយនៅក្នុងករណីខ្លះពុំមានការអនុវត្តដោយភាពសុច្ចរិតនោះទេ គឺនៅមានការក្លែងបន្លំទឹកឃ្មុំព្រៃដែលជាកក្តាមួយធ្វើឱ្យអតិថិជនមានការមន្ទិលសង្ស័យលើគុណភាពទឹកឃ្មុំព្រៃកម្ពុជាដែលកំពុងលក់នៅកលើទីផ្សារ។ ការធ្វើឱ្យទឹកឃ្មុំព្រៃមានគុណភាពល្អ និភាពស្មោះត្រង់ជាចំណុចពិសេសដែលអាចសាងទំនុកចិត្តដល់អ្នកប្រើប្រាស់និងធ្វើឱ្យមានភាពងាយស្រួលក្នុងការស្វែងរកទីផ្សារទឹកឃ្មុំព្រៃនិងជួយធ្វើឱ្យទីផ្សារទឹកឃ្មុំមានស្ថេរភាព។









# ២.ភាពគំរាមគំហែង

ការប្រមូលទឹកឃ្មុំព្រៃរបស់សហគមន៍សម្រាប់ជីវភាពរស់នៅកំពុងតែទទួលការគំរាមគំហែងខ្លាំង ពីព្រោះសត្វឃ្មុំកំពុងតែទទួលការបាត់បង់ពូជឃ្មុំ ដោយសារព្រៃឈើមានការថយចុះ ខ្វះទីជម្រកខ្វះទីកន្លែងសម្រាប់ស្វែងរកចំណីជាដើម។ វិធីសាស្រ្តដ៏ល្អបំផុតនៃការបង្កើតសត្វឃ្មុំព្រៃនិងបង្កើតទឹកឃ្មុំឱ្យបានច្រើនសម្រាប់ចូលរួមរកប្រាក់ចំណូលបន្ថែមដល់សហគមន៍យើង គឺយើងត្រូវចូលរួមការពារព្រៃឈើឱ្យបានគង់វង្ស និង នាំគ្នាអនុវត្តបច្ចេកទេសយកឃ្មុំព្រៃប្រកបដោយនិរន្តរភាព។



# ៣.លក្ខណៈជីវសាស្ត្ររបស់សត្វឃ្មុំព្រៃ

ឃ្មុំជាសត្វមួយប្រភេទដែលរស់នៅក្នុងសំបុក និងមានស្តេចស្រីជាសត្វឃ្មុំដែលសំខាន់ជាងគេបំផុតនៅក្នុងសំបុក វាមានមាឌរាងធំជាងគេនិងមានពោះវែង។ ជាធម្មតានៅក្នុងសំបុកមានតែឃ្មុំស្តេចស្រីតែមួយប៉ុណ្ណោះ និងមានតួនាទីបង្កើតពងញាស់ វាអាចពងជាប្រមាណ១០០០ ពង ក្នុង១ថ្ងៃ ហើយអាចរស់បានពី ៣ទៅ៤ឆ្នាំ។

ឃ្មុំកម្មករមានចំនួនច្រើនជាងគេនៅក្នុងសំបុក ឃ្មុំកម្មករទាំងអស់សុទ្ធតែឃ្មុំញី ហើយអាចទិញបាន។ ឃ្មុំកម្មករអាចរស់បានត្រឹមតែ៤ទៅ៦សប្តាហ៍ប៉ុណ្ណោះគឺនៅក្នុងអំឡុងរដូវទឹកឃ្មុំ វាមានតួនាទីស្វែងរកចំណី(លម្អងផ្កា)មកចិញ្ចឹមសំបុក។

# ៣.លក្ខណៈជីវសាស្រ្តរបស់សត្វឃ្មុំព្រៃ( ត )

ឃ្មុំឈ្មោលជាឃ្មុំដែលគ្មានទ្រនិចទិចបានទេ វាមានផ្នែកធំៗ ពោះរាងមូលនិងមាំនស្លាបខ្លី ។ ឃ្មុំឈ្មោលមានតួនាទីតែមួយគត់គឺស្វែងរកស្តេចស្រីសម្រាប់បង្កាត់ពូជ ប៉ុន្តែបន្ទាប់ពីបង្កាត់ពូជរួច ឃ្មុំឈ្មោលត្រូវងាប់។







# ៤.ប្រភេទសត្វឃ្មុំនៅកម្ពុជា

- **នៅក្នុងប្រទេសកម្ពុជាយើងឃ្មុំមាន៦ប្រភេទគឺ៖**

១.ឃ្មុំធំ(ឃ្មុំចង្អេរឬ ឃ្មុំត្រចៀកដំរី) ជាឃ្មុំមួយប្រភេទដែលធ្វើសំបុកនៅលើដើមឈើធំខ្ពស់ៗ ដែលមានទំហំ ប្រវែណាយចន្លោះ១មទៅ១.៥០ម និងកម្ពស់ ០.៨ម ទៅ ១ម ហើយឃ្មុំប្រភេទនេះអាចមាន ១សំបុក ឬ ច្រើនសំបុកនៅលើដើមឈើតែមួយ។

២. ព្រួត ជាប្រភេទឃ្មុំដែលចូលចិត្តធ្វើសំបុកនៅក្នុងរន្ធឈើ ហើយផលិតទឹកឃ្មុំនៅក្នុងសំបុកជាបន្ទះៗ។ ព្រួតត្រូវបានគេចិញ្ចឹមនៅក្នុងប្រអប់។

៣. ម្រុំ ជាប្រភេទឃ្មុំដែលចូលចិត្តធ្វើសំបុកក្នុងតំបន់ព្រៃ នៅក្នុងដំបូកកណ្តៀរ។

# ៤.ប្រភេទសត្វឃ្មុំនៅកម្ពុជា( ត )



ជញ្ជាំងថ្មនិងរន្ធផ្សេងៗទៀត។ ម្រំធ្វើសំបុកដោយមានទ្វាររាងស៊ីទ្បាំងអាចហើរចេញចូលបាន។

៤. ឃ្មុំអឺរ៉ុប ឬ ឃ្មុំស្រុក ជាឃ្មុំប្រភេទដែលគេយកមកចិញ្ចឹមនៅក្នុងប្រអប់(ឃ្មុំចិញ្ចឹម)។

៥. ឃ្មុំផ្លិតជាប្រភេទឃ្មុំដែលមានសំបុកតូចៗ និងចូលចិត្តធ្វើសំបុកនៅតាមព្រៃ ឬកំប៉ុតស្មៅតូចៗ ។

៦. ប្រភេទឃ្មុំអាចម៍ឆ្កែឬឃ្មុំអង្គញជាឃ្មុំដែលចូលចិត្តរស់នៅតាមព្រៃវាលលើដើមឈើតូចៗ ។



# ៥. អត្ថប្រយោជន៍ឃ្មុំនិងទឹកឃ្មុំព្រៃ



- ដំណើរលំអងផ្ការុក្ខជាតិ

  និង ដំណាំ

- ទឹកឃ្មុំ
- ក្រមួន
- ខ្សែសង្វាក់ចំណីអាហារ



# ៥. អត្ថប្រយោជន៍ឃ្មុំនិងទឹកឃ្មុំព្រៃ(ត)







# ➢ ផលប្រយោជន៍ទឹកឃ្មុំព្រៃ

- ជួយរក្សាតុល្យភាពរាងកាយនិងរក្សាទម្ងន់ ជួយបញ្ចុះកម្រិតខ្លាញ់អាក្រក់នៅក្នុងរាងកាយបានលឿន ជួយព្យាបាលជម្ងឺ ក្អក ឈឺក ផ្លាសសាយ ឈឺសន្លាក់ដៃជើង គ្រេចថ្លោះ ឈឺសសៃ...
- ជួយបញ្ចុះសម្ពាធឈាម និងជួយកាត់បន្ថយជម្ងឺបេះដូង ជួយសម្រួលដល់ចលនាឈាមឱ្យមានដំណើរការល្អ
- ជួយសម្រួល និងកាត់បន្ថយជម្ងឺសម្រាកពុំលក់
- នៅក្នុងទឹកឃ្មុំមានជាតិអង់ហ្សីមជួយផ្តល់សំណើមដល់ស្បែក និងស្បែកមុខ ស មដ្ឋរលោងស្រស់ស្អាត ក្មេងជាងវ័យ
- ជួយបន្សាបជាតិពុលនៅក្នុងរាងកាយ និងនៅក្នុងថ្លើម
- ជួយជំនួយស្មារតីរឹងមាំ បំបាត់ភាពស្ត្រេស ជម្ងឺបាក់ទឹកចិត្ត
- ជួយជម្រុញអាហារឱ្យមានរស់ជាតិឈ្ងុយឆ្ងាញ់និងជួយ ឱ្យអ្នកបរិភោគមានសុខភាពល្អប្រកបដោយសុវត្ថិភាព





## ៦. បច្ចេកទេសការប្រមូលនិងការគ្រប់គ្រងទឹកឃ្មុំប្រកបដោយនិរន្តរភាព

ក) លក្ខខណ្ឌឃ្មុំព្រៃ

- ឃ្មុំព្រៃគឺជាឃ្មុំដែលប្រមូលចេញពីឃ្មុំធំ(ឃ្មុំចង្អេរឬឃ្មុំស្លឹកត្រចៀកដំរី ដែលមាននៅក្នុងព្រៃធម្មជាតិ ដូចជាព្រៃកោងកាង ព្រៃតំបន់ ដីសើម តំបន់ភ្នំ ជាពិសេសតំបន់ព្រៃការពារ ឬព្រៃសហគមន៍តែប៉ុណ្ណោះ ។
- ត្រូវគោរពប្រពៃណី ព្រៃឈើជនជាតិដើមភាគតិច និងក្បួនតម្រាផ្សេងៗរបស់ពួកគាត់ ។
- ត្រូវគោរពភាពជាម្ចាស់ តាមបែនប្រពៃណីនៃដើមឈើ ដែលឃ្មុំធ្វើសំបុក និងធ្វើបង្គង។
- ប្រតិបត្តិតាមរដូវកាលនៃការប្រមូលទឹកឃ្មុំព្រៃ។

# ៦. បច្ចេកទេសការប្រមូលនិងការគ្រប់គ្រងទឹកឃ្មុំប្រកបដោយនិរន្តរភាព(ត)



- ការប្រមូលទឹកឃ្មុំនៅរដូវប្រាំង អាចចាប់ផ្តើមពីខែមីនា ដល់ខែឧសភា  ហើយរដូវវស្សាចាប់ពីខែមិថុនា ដល់ខែកញ្ញា ។
- ប្រមូលតែផ្ទិតណាចាស់ ឬទឹកឃ្មុំចាស់នៅពេលដែលក្មោសិកាប្រមូនឃ្មុំបិទជិតហើយក្បាលទឹកឡើងក្រាស់ ។
- ការប្រមូលឃ្មុំគឺត្រូវធ្វើឡើងនៅពេលមានកម្តៅថ្ងៃល្អ ចាប់ពីចន្លោះម៉ោង៩ព្រឹក ដល់ម៉ោង៤ល្ងាច ពីព្រោះនៅក្នុងរយៈពេលនេះមេឃ្មុំភាគច្រើនចេញពីសំបុកទៅរកលម្អងផ្កា នឹងទឹកដបក្នុងការចិញ្ចឹមកូនឃ្មុំ ។
- ត្រូវងូតទឹកសម្អាតខ្លួនឱ្យបានស្អាតនិងជៀសវាងប្រើគ្រឿងក្រអូបដូចជាម្សៅ ទឹកប់ និងក្លិនស្អុយ ពីព្រោះក្លិនចំឡែកសត្វឃ្មុំរួមទិចពេញខ្លួន។



# ៦. បច្ចេកទេសការប្រមូលនិងការគ្រប់គ្រងទឹកឃ្មុំប្រកបដោយនិរន្តរភាព(ត)



- ដើម្បីការពារសុវត្ថិភាព ពេលឡើងយកឃ្មុំព្រៃ ត្រូវស្លៀកសំលៀកបំពាក់ សម្រាប់ប្រមូលយកឃ្មុំឬ យ៉ាងហោចណាស់ មាន ពាក់មួកការពារ ពាក់អាវដៃវែងក្រាស ខោជើងវែងក្រាស់ មានពាក់ស្រោមដៃ និងស្រោមជើង សម្រាប់ការពារកុំឱ្យឃ្មុំទិច។



# ៦. បច្ចេកទេសការប្រមូលនិងការគ្រប់គ្រងទឹកឃ្មុំប្រកបដោយនិរន្តរភាព(ត)



- ត្រូវប្រមូលតែសំបុកឃ្មុំណាដែលគ្រប់អាយុពេញក្បាលទឹកល្អឬចាស់ល្អ ដែលមានលក្ខណៈកោសិកាក្រមួនបិទជិត និង មានក្បាលទឹកឡើងក្រាស់ល្អ។
- ប្រមូលយកតែចំនួន៨០% ដោយរក្សាទុក(កូនឃ្មុំ និងផ្លិតឃ្មុំ)មួយចំនួន ដើម្បីឱ្យឃ្មុំបង្កសំបុកថ្មីបន្ត។
- ពេលយកត្រូវប្រើផ្សែងគួបពណ៌ស ក្នុងការបោសដេញមេឃ្មុំចេញពីសំបុក ដើម្បីងាយស្រួលយកឃ្មុំ។



# ៦. បច្ចេកទេសការប្រមូលនិងការគ្រប់គ្រងទឹកឃ្មុំប្រកបដោយនិរន្តរភាព(ត)

- ពេលយកឃ្មុំមិនត្រូវ ប្រើភ្លើងឬ ថ្នាំសម្លាប់សត្វនោះទេ ព្រោះវានាំឱ្យឃ្មុំផុតពូជ។
- ដើម្បីភាពងាយស្រួលត្រូវប្រើខ្សែយោងវែងសម្រាប់ចង់គប់ផ្សែង យកឡើងទៅលើនិងសម្រាប់ចង់ថុងឬកានទឹកឃ្មុំដាក់ចំមកវិញ។
- មិនត្រូវយកឃ្មុំនៅពេលយប់នោះទេ ព្រោះធ្វើឱ្យឃ្មុំងាប់ច្រើន អាចផុតពូជឃ្មុំ។
- ត្រូវគោរពធ្វើតាមច្បាប់នានា ដូចជាច្បាប់ព្រៃឈើ ច្បាប់ការពារតំបន់ការពារធម្មជាតិ

ច្បាប់ការពារសហគមន៍ព្រៃឈើ ជាដើម និងធ្វើការតាមដានទៅលើការអនុវត្តច្បាប់ទាំងនោះ មានដូចជា៖

> មិនត្រូវបរបាញ់សត្វព្រៃ ឬដុតឬកាប់បំផ្លាញព្រៃឈើ និងនាំយកឆ្កែទៅជាមួយ។

> មិនត្រូវប្រមូលយកអនុផលព្រៃឈើនៅក្នុងតំបន់ឈ្នួល ឬតំបន់ហាមឃាត់។





# ៦. បច្ចេកទេសការប្រមូលនិងការគ្រប់គ្រងទឹកឃ្មុំប្រកបដោយនិរន្តរភាព( ត )



ក) ដំណាក់កាលប្រមូលទឹកឃ្មុំ

- នៅពេលប្រមូលក្បាលទឹកឃ្មុំពីក្នុងព្រៃ
- យើងត្រូវប្រើកានឬថុងស្អាត ស្ងួត កាំបិទឈើឬរស្សី ស្បៃស្អាត សម្រាប់ត្រងទឹកឃ្មុំ ស្រោមដៃ។
- កំឡុងពេលនឹង យើងត្រូវប្រើថង់ប្លាស្ទិចធំល្មម(ស្អាត ថ្មី) សម្រាប់ចូលក្នុងថុងឬកានសម្រាប់ដាក់ទឹកឃ្មុំដែលយកបានថ្មីៗ ។






# ៦.១ ការកែច្នៃនិងការត្រួតពិនិត្យគុណភាពទឹកឃ្មុំ



- បន្ទាប់ពីប្រមូលយកក្បាលទឹកឃ្មុំព្រៃរួចរាល់ យើងត្រូវចង់មាត់ថង់ភ្លាមៗ ចៀសវាងការចម្លងមេរោគពីខាងក្រៅ (ការធ្វើការជាមួយទឹកឃ្មុំត្រូវមានអនាម័យខ្ពស់បំផុត)។
- យកល្អត្រូវត្រូវយកឃ្មុំទាំងក្បាលទឹកមកលក់ជូនគណៈកម្មការប្រមូលទិញទឹកឃ្មុំទើបល្អ ។
- **កម្រិតជាតិទឹកនៅក្នុងទឹកឃ្មុំ**
  - ទឹកឃ្មុំព្រៃយកនៅរដូវប្រាំង មានកម្រិតជាតិទឹកពី ក្រោម **២៤%**
  - ទឹកឃ្មុំព្រៃយកនៅរដូវវស្សា មានកម្រិតជាតិទឹកពី ក្រោម **២៩%**(ត្រូវការប្រើម៉ាស៊ីនរំងួតជាតិទឹកចេញ) ទឹកឃ្មុំដែលល្អមានកម្រិតជាតិទឹកចន្លោះ **២០-២២%** ។



# ៦.២ របៀបច្រោះទឹកឃ្មុំព្រៃ

## ច្រោះលើកទី១

- ត្រូវងូតទឹកឱ្យស្អាត ដុះខ្លួន ដៃនិងសាប៊ូលាងទឹកឱ្យស្អាត និងជូតដៃឱ្យស្ងួត។
- ត្រូវពាក់ម៉ាស និងពាក់សោមដៃឱ្យបានត្រឹមត្រូវ
- ព្យាយាមរើសកម្ទេចកម្ទីដែលមាននៅក្នុងថុងទឹកឃ្មុំចេញឱ្យអស់ ឬក្បាលទឹក។
- យកកាំបិទឈើឬឬស្សី ពុះក្បាលទឹកឃ្មុំជាចំណិតៗ(ពុះទទឹងក្បាលទឹក)និងដាក់ក្នុងស្បៃច្រោះ *(ដោយទុកឱ្យវាហូរតាមបម្រួលដោយខ្លួនឯង)*ធ្វើបែបនេះ ទទួលបានទឹកឃ្មុំថ្លាល្អ មានគុណភាពល្អ ទុកបានយូរ។





## ៦.៣ ការចម្រោះទឹកឃ្មុំព្រៃលើកទី២ និងការវិចខ្ចប់

- ត្រូវងូតទឹកដុសនិងសាប៊ូ ទាំងខ្លួនប្រាណនិងដៃឱ្យបានស្អាតជាមុន។
- ត្រូវពាក់ម៉ាសនិង ពាក់ស្រោមដៃឱ្យបានត្រឹមត្រូវ។
- ត្រូវធ្វើការពិនិត្យជាតិទឹកនិងគុណភាពនៅក្នុងទឹកឃ្មុំព្រៃ
- ត្រូវប្រើថង់ចម្រោះដែកអ៊ីណុកល្អ លាងនឹងសាប៊ូឱ្យស្អាត ទុកឱ្យស្ងួត បន្ទាប់មកដាក់ក្រណាត់ស្បៃស្អាត ស្ងួត ដាក់ទ្រាប់ 2 ទៅ3 ជាន់ និងទុកឱ្យទឹកឃ្មុំហូរតាមសម្រួលដោយខ្លួនឯង (កន្លែងចម្រោះទឹកឃ្មុំត្រូវប្រាកដថាស្អាត គ្មានដីហុយ )។





# ៦.៤ ការវិចខ្ចប់ទឹកឃ្មុំព្រៃ



- ពេលចម្រោះស្អាតរួចរាល់ ត្រូវមូលក្បាលរុំមីណេចេញពីថុងចម្រោះដាក់ចូលទៅក្នុងកាន(លាងស្អាត ទុកឱ្យស្ងួត) និងមានបិទគម្របកានឱ្យបានជិតល្អ និងត្រូវបិទផ្លាកសញ្ញាទឹកឃ្មុំរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីសុវត្ថិភាព។
- សម្រាប់ការវិចខ្ចប់ដាក់ដបទឹកឃ្មុំតាមខ្នាតនីមួយៗ ត្រូវប្រើសំបកដបថ្មី (លាងនឹងសាប៊ូ លាងទឹកឱ្យស្អាត ទុកឱ្យស្ងួតល្អ) និងមានបិទគម្របជិតល្អ មានបិទផ្លាកសញ្ញារបស់ក្រុមខ្លួនត្រឹមត្រូវ និងមានបិទសីលពីលើដើម្បីសុវត្ថិភាពទឹកឃ្មុំ ពិសេសឱ្យមានសោភ័ណភាព ដើម្បីបង្កើនទំទុកចិត្តនិងការចាប់អារម្មណ៍ដល់អ្នកប្រើប្រាស់។



# ៧. របៀបធ្វើបង្គងឱ្យឃ្មុំធំនៅក្នុងព្រៃសហគមន៍








សូមអរគុណច្រើន !